**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៨៤ សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សា និងដោះស្រាយបញ្ហាបាក់ច្រាំង ទន្លេបាសាក់និងព្រែកជ្រៃធំនៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២៣/០១៨ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសិក្សានិងដោះស្រាយបញ្ហាបាក់ច្រាំងទន្លេបាសាក់និងព្រែកជ្រៃធំតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. ឯកឧត្តម **ឡាំ ជា** | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន | ប្រធាន |
| ២. ឯកឧត្តម **ម៉ី សាគុណ** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |

៣.ឯកឧត្តម **ស្តើង សុខុម** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

៤. ឯកឧត្តម **ស៊ុម សុខម្ភ** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន អនុប្រធាន

៥. ឯកឧត្តម **តូច ចាន់កុសល** រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

៦. ឯកឧត្តម **ម៉ុញ សច្ចះ** រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម សមាជិក

៧. ឯកឧត្តម **យស មុនីរ៉ាត់** អនុរដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល សមាជិក

៨. ឯកឧត្តម **អាន សុវឡ្យនា** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន សមាជិក

៩. ឯកឧត្តម **សួស ប្រាថ្នា** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ សមាជិកអចិន្ត្រៃយ៍

១០. ឯកឧត្តម **គង់ សោភ័ណ្ឌ** អភិបាលនៃគណៈអភិបាលខេត្តកណ្តាលសមាជិក

១១. ឯកឧត្តម **តែ ណាវុធ** អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សមាជិក

១២. លោក **ណៃ ចំណង់** អគ្គនាយករងនៃអគ្គនាយកដ្ឋានសាធារណការ ក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

១៣. លោក **អ៊ុក មុនិន្ទ** ប្រធាននាយកដ្ឋានអាជីវកម្មរ៉ែខ្សាច់សំណង់ អគ្គនាយកដ្ឋានរ៉ែ ក្រសួងរ៉ែនិងថាមពល សមាជិក

១៤. លោក **យុន ចំរើន** ប្រធាននាយកដ្ឋានឯកសារនិងផ្សព្វផ្សាយនៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន សមាជិក

១៥. លោក **ឡៅ សុខសំភា** ប្រធាននាយកដ្ឋានកិច្ចការព្រំដែន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៦. ឧត្តមសេនីយ៍ឯក **ឈៀង ភារម្យ** ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន សមាជិក

១៧. លោក **ឆាង ច័យ** ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត សមាជិក

១៨. លោក **ឈឿន សុចិត្រ** ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល សមាជិក

១៩. លោក **អេង សុវិចិត្រ** អភិបាលក្រុងសំពៅពូន

២០. លោក **គង់ សុវណ្ណរង្សី** អនុប្រធានការិយាល័យកិច្ចសហប្រតិបត្តិការ សមាជិក

**ប្រការ២ ..**

គណៈកម្មការខាងលើនេះមានមុខងារនិងភារកិច្ចដូចខាងក្រោមៈ

– សិក្សា ស្រាវជ្រាវ និងវាយតម្លៃអំពីហេតុផលប៉ះពាល់បរិស្ថាននិងសង្គមដែលបណ្តាលមកពីការបាក់ច្រាំងទន្លេបាសាក់និងព្រែកជ្រៃធំតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម

- ពិភាក្សា ចរចា និងដាក់ចេញដំណោះស្រាយលើបញ្ហាបាក់ច្រាំងទន្លេបាសាក់និងព្រែកជ្រៃធំ
- ចាត់វិធានការសមស្របដើម្បីបង្ការនិងទប់ស្កាត់ការបាក់ច្រាំងនៅតាមបណ្ដោយព្រំដែនកម្ពុជា-វៀតណាម ថែរក្សាការពារស្ថិរភាពនៃខ្សែបន្ទាត់ព្រំដែន ច្រាំងព្រំដែន និងបង្គោលព្រំដែន
- សម្របសម្រួល ពិភាក្សា និងចរចាជាមួយភាគីវៀតណាមដើម្បីរិះរកមធ្យោបាយដែលមានលក្ខណៈបុរេសកម្មក្នុងការដោះស្រាយបញ្ហាបាក់ច្រាំងទន្លេបាសាក់និងព្រែកជ្រៃធំតាមបណ្ដោយព្រំដែនកម្ពុជា-វៀតណាម
- រៀបចំនិងអនុវត្តផែនការសកម្មភាពនិងផែនការថវិកា ដើម្បីបង្ការ ទប់ស្កាត់ និងដោះស្រាយបញ្ហាបាក់ច្រាំងទន្លេបាសាក់និងព្រែកជ្រៃធំតាមបណ្ដោយព្រំដែនកម្ពុជា-វៀតណាម
- រៀបចំគម្រោងថវិកាចំណាយលម្អិតសម្រាប់សាងសង់ច្រាំងទន្លេនិងព្រែកនៅទីតាំងបាក់ច្រាំង ដែលស្ថិតក្នុងស្ថានភាពហានិភ័យជាក់ស្ដែង ដើម្បីដាក់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ សម្រេច
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងនៃការសាងសង់ច្រាំងទន្លេបាសាក់និងព្រែកជ្រៃធំតាមបណ្ដោយព្រំដែនកម្ពុជា-វៀតណាម
- រៀបចំរបាយការណ៍ស្ដីពីលទ្ធផលសម្រេចបាននិងវឌ្ឍនភាពការងារជូនប្រមុខរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៣ ..**

ប្រធានគណៈកម្មការអន្តរក្រសួងត្រូវរាយការណ៍សុំយោបល់ដឹកនាំជាប្រចាំពីប្រមុខរាជរដ្ឋាភិបាល ក្នុងការអនុវត្តការងាររបស់ខ្លួន។

អនុប្រធាននិងសមាជិកគណៈកម្មការអន្តរក្រសួងត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីអនុប្រធានឬសមាជិកណាម្នាក់អវត្តមាន រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមីត្រូវចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចឱ្យចូលរួមប្រជុំជំនួស។

អនុប្រធាននិងសមាជិកគណៈកម្មការអន្តរក្រសួងត្រូវបំពេញការងារតាមការប្រគល់ពីប្រធានគណៈកម្មការអន្តរក្រសួង។

តាមតម្រូវការចាំបាច់នៃការងារ ប្រធានគណៈកម្មការអន្តរក្រសួងមានសិទ្ធិកោះអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធដែលពុំមែនជាសមាជិកគណៈកម្មការអន្តរក្រសួង ឱ្យចូលរួមប្រជុំពិភាក្សាដើម្បីស្វែងរកដំណោះស្រាយទាក់ទងនឹងបញ្ហាបាក់ច្រាំងនេះ។

**ប្រការ៤ ..**

គណៈកម្មការអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនដើម្បីចាត់ចែងការងាររបស់ខ្លួន។

គណៈកម្មការអន្តរក្រសួងមានថវិកាសម្រាប់គាំទ្រដល់កិច្ចប្រជុំទ្វេភាគី និងកិច្ចដំណើរការការងាររបស់ខ្លួន ដែលមានប្រភពពីថវិកាជាតិ ស្ថិតក្នុងកញ្ចប់ថវិការបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

ចំណាយលើការសាងសង់សំណង់និងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ថែរក្សាការពារស្ថិរភាពនៃខ្សែបន្ទាត់ព្រំដែន ច្រាំងព្រំដែន និងបង្គោលព្រំដែនស្ថិតនៅទន្លេបាសាក់និងព្រែកជ្រៃធំ តាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ស្ថិតក្នុងកញ្ចប់ថវិកាដោយឡែក ក្រោមអាណាប័កនៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

ចំណាយក្នុងការរៀបចំកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួងទាំងក្នុងនិងក្រៅប្រទេស មធ្យោបាយ និងសម្ភារផ្សេងៗ ការសិក្សា ស្រាវជ្រាវ ការបំពេញបេសកកម្មរបស់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការអន្តរក្រសួង ស្ថិតក្នុងកញ្ចប់ថវិការបស់ក្រសួង ស្ថាប័នសាមី។

**ប្រការ៥** .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦** .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៩កើត ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែ វិច្ឆិកា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ